រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

# របាយការណ៍
# ស្ដីពី
# លទ្ធផលវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ
# សង្កាត់
# សម្រាប់អាណត្តិទី២ ឆ្នាំ២០០៧-២០១២

រៀបរៀងដោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ

ខែកញ្ញា ឆ្នាំ២០១២

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញពីឆន្ទៈរបស់ខ្លួនយ៉ាងមុតមាំ ក្នុងការសម្រេចឱ្យបាននូវការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ដើម្បីធានាដល់ការរួមចំណែកការអភិវឌ្ឍមូលដ្ឋានតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ ការបង្កើនសុខុមាលភាព និងការឆ្លើយតបចំពោះសេចក្តីត្រូវការរបស់មូលដ្ឋានសំដៅរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

តាមរយៈនៃការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ឃុំ សង្កាត់បានដំណើរការជ្រើសរើសក្រុមប្រឹក្សារបស់ខ្លួនចាប់តាំងពីឆ្នាំ២០០២ ស្របតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ទោះបីជាដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានលក្ខណៈស្មុគស្មាញយ៉ាងណាក៏ដោយ ក៏ ក្រុមប្រឹក្សាឃុំ សង្កាត់បានដំណើរការងាររបស់ខ្លួនយ៉ាងរលូនអស់រយៈពេលជាង១០ឆ្នាំមកហើយ។ ក្រោយពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់នៅអាណត្តិទី៣ នា ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ១១.៤៥៩ រូប នឹង បន្តការងារចាត់ចែង គ្រប់គ្រង និងអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនចំនួន ១.៦៣៣ ឃុំ សង្កាត់ សម្រាប់រយៈពេល០៥ឆ្នាំខាងមុខ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៧។

ដើម្បីផ្តល់សារប្រយោជន៍ក្នុងការរៀនសូត្រអំពីចំណុចខ្លាំង និងចំណុចខ្សោយ រួមទាំងការទាញយកនូវបទពិសោធន៍ល្អៗសំដៅកែលម្អការដឹកនាំគ្រប់គ្រងឃុំ សង្កាត់ និងការផ្តល់សេវាសាធារណៈឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់ ក្រសួងមហាផ្ទៃបានណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ឱ្យធ្វើការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់សម្រាប់អាណត្តិទី២ ឆ្នាំ២០០៧-២០១២។ ការវាយតម្លៃនេះ គឺជាការវាយតម្លៃផ្ទៃក្នុងរបស់ឃុំ សង្កាត់ដោយមានការគាំទ្រពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលផ្តោតទៅលើលទ្ធផល និងប្រសិទ្ធភាពនៃកិច្ចអភិវឌ្ឍន៍ និងការផ្តល់សេវាសាធារណៈរបស់ឃុំ សង្កាត់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ដោយមើលឃើញពីគុណប្រយោជន៍នៃការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់ ក្រសួងមហាផ្ទៃបានធ្វើការបូកសរុបលទ្ធផលនៃការវាយតម្លៃទាំងនេះ ជារបាយការណ៍បូកសរុបស្តីពី លទ្ធផលវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់សម្រាប់អាណត្តិទី២ ឆ្នាំ២០០៧-២០១២ ដើម្បីទុកជាជំនួយស្មារតីដល់ស្ថាប័នគាំទ្រទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកកែលម្អ និងពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ និងការអភិវឌ្ឍតាមបែបប្រជាធិប្បតេយ្យនៅថ្នាក់ក្រោមជាតិ។

*រាជធានីភ្នំពេញ ថ្ងៃទី.........ខែ............ឆ្នាំ២០១២*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

# មាតិកា

## ផ្នែកទី I. សេចក្តីផ្តើម


១. សេចក្តីផ្តើម ........ ០១
២. វិធីសាស្រ្តនៃការវាយតម្លៃ ........ ០១


## ផ្នែកទី II. លទ្ធផលរកឃើញ


១. ការបូកសរុបលទ្ធផលការងារឃុំ សង្កាត់ សម្រាប់អាណត្តិទី២ ........ ០២
១.១. ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ........ ០២
១.២. ការអនុវត្តមុខងារជាភ្នាក់ងារ ........ ០៤
១.៣. ការអនុវត្តផែនការ និងកម្មវិធីវិនិយោគ ........ ០២
១.៤. ការអនុវត្តថវិកាឃុំ សង្កាត់ ........ ០៦
២. ប្រសិទ្ធភាពនៃកិច្ចអភិវឌ្ឍ ការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវាកម្មឃុំ សង្កាត់ ........ ០៨
២.១. ការ គ្រប់គ្រងរដ្ឋបាល ........ ០៩
២.២. ការ អនុវត្តមុខងារជាភ្នាក់ងារ ........ ១១
២.៣. ការ គ្រប់គ្រងហិរញ្ញវត្ថុ ........ ១២
២.៤. ការគ្រប់គ្រងមូលនិធិឃុំ សង្កាត់ ........ ១៣
២.៥. ការពង្រឹងសមត្ថភាពឃុំ សង្កាត់ ........ ១៤
២. ៦. កិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ........ ១៥


## ផ្នែកទី III. អនុសាសន៍កែលម្អ


១. ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ........ ១៦
២. ការអនុវត្តមុខងារជាភ្នាក់ងារ ........ ២០
៣. ការគ្រប់គ្រងហិរញ្ញវត្ថុ ........ ២១
៤. ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ ........ ២៣
៥. កិច្ចសហការជាមួយក្រសួង ........ ២៣


## ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១៖ លទ្ធផលរីកចម្រើន និងលទ្ធផលសម្រេចបានរបស់ឃុំ សង្កាត់ ........ ២៤
ឧបសម្ព័ន្ធទី២៖ ប្រសិទ្ធភាព និងដំណើរការ(ដោយក្រុមប្រឹក្សាឃុំ សង្កាត់) ........ ២៨
ឧបសម្ព័ន្ធទី៤៖ ប្រសិទ្ធភាព និងដំណើរការ(ដោយប្រជាពលរដ្ឋ) ........ ៥៤

# ផ្នែកទី I
# សេចក្ដីផ្ដើម

# ផ្នែកទី I
# សេចក្តីផ្តើម

## ១. សេចក្តីផ្តើម

ឃុំ សង្កាត់ គឺជានីតិបុគ្គលដែលត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតនាថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០២ និងមានអាណត្តិរបស់ខ្លួនរយៈពេល ០៥ឆ្នាំ។ នេះជាអាណត្តិទី២ហើយ ក្នុងការអនុវត្តប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់ឃុំ សង្កាត់ ដែលមានគោលដៅ ដើម្បីជំរុញលទ្ធិប្រជាធិបតេយ្យដោយមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋាន លើកស្ទួយសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ។ ចាប់តាំងពីឆ្នាំ២០០៧មក ក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន១.៦២១ នៅទូទាំងប្រទេស ដែលមានសមាជិកសរុបចំនួន១១.៣៥៣រូប ក្នុងនោះមានសមាជិកជាស្ត្រីចំនួន១.៨៥៩រូប បាននិងកំពុងបំពេញការងារដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។ នៅដើមឆ្នាំ២០១២ខាងមុខនេះ ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២នឹងបញ្ចប់អាណត្តិរបស់ខ្លួន ហើយត្រូវចូលមកជំនួសដោយក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីសម្រាប់អាណត្តិទី៣ ជាបន្តទៀត។ ការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់មានគោលបំណង ដូចខាងក្រោម៖

- ដើម្បីពិនិត្យ និងបូកសរុបលទ្ធផលនៃការអនុវត្តគម្រោងអភិវឌ្ឍន៍ និងការផ្តល់សេវាកម្មរបស់ឃុំ សង្កាត់។
- ដើម្បីសិក្សាអំពីប្រសិទ្ធភាព និងផលប៉ះពាល់នៃកិច្ចអភិវឌ្ឍន៍ ការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវាកម្មរបស់ឃុំ សង្កាត់។
- ដើម្បីចែករំលែកបទពិសោធន៍ និងផ្តល់អនុសាសន៍ក្នុងការកែលម្អ និងពង្រឹងតួនាទីភារកិច្ច ការគ្រប់គ្រងរដ្ឋបាល កិច្ចអភិវឌ្ឍន៍ និងការផ្តល់សេវាកម្មរបស់ឃុំ សង្កាត់។

ការបូកសរុបលទ្ធផលវាយតម្លៃផ្ទៃក្នុងលើកិច្ចការរបស់ឃុំ សង្កាត់សម្រាប់អាណត្តិទី២ នៅថ្នាក់រាជធានី ខេត្តនេះ គឺដើម្បីស្វែងយល់នូវការរីកចម្រើននៃការអនុវត្តប្រព័ន្ធវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ កំណត់បញ្ហានានា និងអនុសាសន៍ល្អៗសម្រាប់កែលម្អ និងផ្តល់ការគាំទ្រដល់ឃុំ សង្កាត់នាអាណត្តិបន្ទាប់។

## ២. វិធីសាស្ត្រក្នុងការបូកសរុបទិន្នន័យ

ក្នុងការរៀបចំរបាយការណ៍បូកសរុបស្តីពីលទ្ធផលវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់នេះ ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត បានប្រមូលព័ត៌មានពីគ្រប់ឃុំ សង្កាត់ទាំងអស់ក្នុងនោះរួមមាន របាយការណ៍វាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់ និងតារាងទិន្នន័យ តាមរយៈមន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ និងទីប្រឹក្សាក្រុងស្រុក។ ទិន្នន័យទាំងនេះ ត្រូវបានវាយបញ្ចូលក្នុងកម្មវិធីអ៊ិចសែល ដើម្បីធ្វើការវិភាគ និងបូកសរុបនៅទូទាំងរាជធានី ខេត្ត ដោយស្របតាមទម្រង់ដែលបានណែនាំដោយក្រសួងមហាផ្ទៃ។

# ផ្នែកទី II

# លទ្ធផលរកឃើញ

## ផ្នែកទី II
# លទ្ធផលរកឃើញ

## ១. ការបូកសរុបលទ្ធផលការងារឃុំ សង្កាត់ សម្រាប់អាណត្តិទី២

ការពិពណ៌នាខាងក្រោមនេះ ផ្អែកលើការវិភាគទិន្នន័យក្នុងរបាយការណ៍ទម្រង់ទី១ (លទ្ធផលសម្រេចបានសម្រាប់អាណត្តិទី២របស់ក្រុមប្រឹក្សាឃុំ សង្កាត់) ដែលរាជធានី ខេត្តបានបូកសរុបរបាយការណ៍ស្តីពីលទ្ធផលការវាយតម្លៃកិច្ចការផ្ទៃក្នុងឃុំ សង្កាត់របស់ឃុំ សង្កាត់នីមួយៗ។

## ១.១ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

### ១.១.១ សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងអាណត្តិទី២ (២០០៧-២០១១) របស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានចូលកាន់តំណែងសរុបមានចំនួន ១១៤៧៤ រូប ដែលក្នុងនោះស្ត្រី មានចំនួន ១៥ % មានការកើនឡើងតិចតួច បើប្រៀបធៀបទៅអាណត្តិទី១។ ការផ្លាស់ប្តូរសមាជិកភាព អាចកើតមានចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ រូបណា ដែលមានករណីសាមីខ្លួនទទួលមរណភាព បាត់បង់កាយសម្បទាវិជ្ជាជីវៈ ការសុំលាលែង ការផ្តន្ទាទោស ឬការបណ្តេញចេញជាដើម។




ជាក់ស្តែងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានផ្លាស់ប្តូរមានចំនួន ១២ % ដែលស្មើចំនួនប្រហាក់ប្រហែល ១៣៨១ រូប ក្នុងនោះស្ត្រីមានចំនួន ១៥ភាគរយ។

### ១.១.២. ស្មៀនឃុំ សង្កាត់

ស្មៀនឃុំ សង្កាត់គឺជាបុគ្គលិកក្របខណ្ឌដែលទទួលបានការតែងតាំងពីក្រសួងមហាផ្ទៃ ដើម្បីជួយកិច្ចការក្រុមប្រឹក្សាឃុំ សង្កាត់។ គ្រប់ឃុំ សង្កាត់ត្រូវមានស្មៀនឃុំ សង្កាត់មួយរូប ក្រៅពីនោះ គេសង្កេតឃើញ ជំនួយការស្មៀនឃុំ សង្កាត់មួយចំនួនទៀតដែលបានចូលបម្រើការងារនៅថ្នាក់ឃុំ សង្កាត់។ នៅក្នុងដំណាច់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២នេះ ចំនួនស្មៀនជាស្ត្រីមានត្រឹម១១ភាគរយ។ ការផ្លាស់ប្តូរស្មៀនជាមធ្យមមានចំនួន ២០ភាគរយ។ ក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិស្នើសុំផ្លាស់ប្តូរស្មៀនឃុំ សង្កាត់ ប៉ុន្តែការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់ថ្មីត្រូវចេញដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

### ១.១.៣. បុគ្គលិកជំនួយការ

ឃុំ សង្កាត់មានសិទ្ធិក្នុងការជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌក្នុងការជួយគាំទ្រកិច្ចការបច្ចេកទេសដល់ឃុំ សង្កាត់។ បុគ្គលិកជំនួយការមានចំនួនសរុប ២៤០៣ រូប ដែលជាបុគ្គលិកក្រៅក្របខណ្ឌ ឬបុគ្គលិកជាប់កិច្ចសន្យា។ គិតជាមធ្យមក្នុងឃុំ សង្កាត់នីមួយៗ ទូទាំងប្រទេសមានបុគ្គលិកយ៉ាងតិច០១ រូបដែរ ដែលឃុំ សង្កាត់មានលទ្ធភាពក្នុងការផ្តល់កិច្ចសន្យាស្របតាមតម្រូវ និងនីតិវិធីដែលបានណែនាំ។

### ១.១.៤. គណៈកម្មាធិការ

គណៈកម្មាធិការសំខាន់ៗរបស់ឃុំ សង្កាត់រួមមាន គណៈកម្មាធិការកសាងផែនការ និងថវិកា គណៈកម្មាធិការស្ត្រី និងកុមារ គណៈកម្មាធិការលទ្ធកម្មជាដើម។ គណៈកម្មាធិការទាំងនេះ ត្រូវបានបង្កើតឡើងស្របតាមការណែនាំ ដែលមានសមាសភាពចំណុះសម្រាប់ជួយកិច្ចការឃុំ សង្កាត់។ មេឃុំ ចៅសង្កាត់ ជាទូទៅជាប្រធានគណៈកម្មាធិការខាងលើ។ នៅក្នុងអាណត្តិទី២នេះ គណៈកម្មាធិការនូវថ្នាក់ឃុំ សង្កាត់ជាមធ្យមចំនួន ១០ ដែលត្រូវបានបង្កើតឡើងពាក់ព័ន្ធការងារក្រុមប្រឹក្សាឃុំ សង្កាត់។

### ១.១.៥. កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់តម្រូវឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការប្រជុំប្រចាំខែ ក្រៅពីនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចធ្វើការប្រជុំវិសាមញ្ញបានបន្ថែមទៀត។ ជាទូទៅ កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងអាណត្តិទី២នេះ មានសកម្មភាពផុសផុលដែលជាមធ្យម ក្រុមប្រឹក្សាឃុំ សង្កាត់ប្រជុំប្រចាំខែបានរហូត ១០៥% ។ មានន័យ ថាបើទោះបីឃុំ សង្កាត់ខ្លះមិនបានប្រជុំទៀងទាត់ ក៏ប៉ុន្តែឃុំ សង្កាត់មួយចំនួនទៀតបានប្រជុំច្រើនលើសពីមួយលើក។




ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តម្រូវឱ្យប្រជាពលរដ្ឋមានសិទ្ធិចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន និងមានសិទ្ធិសង្កេតការ ផ្តល់យោបល់នៅក្នុងកិច្ចប្រជុំប៉ុន្តែមិនមានសិទ្ធិសម្រេចនោះទេ។

របាយការណ៍កិច្ចប្រជុំប្រចាំខែមានចំនួនប្រែប្រួលរវាងឃុំ សង្កាត់មួយទៅឃុំ សង្កាត់មួយទៀត។ ទោះជាយ៉ាងណា កំណត់ហេតុកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់មានត្រឹម ៩៧ភាគរយតែប៉ុណ្ណោះ។

### ១.១.៦. ការគ្រប់គ្រងឯកសារឃុំ សង្កាត់

ឯកសារលិខិតបទដ្ឋានឃុំ សង្កាត់សំខាន់ៗ ដែលបានលើកឡើងនៅក្នុងរបាយការណ៍វាយតម្លៃកិច្ចការឃុំ សង្កាត់ក្នុង អាណត្តិទី២នេះរួមមានដីកា សេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗ។ គិតជារួម នៅទូទាំងប្រទេសយ៉ាងតិចក៏មានចំនួន០៦ដីកា ដែលឃុំ សង្កាត់សាមីបានអនុម័ត និងដាក់ឱ្យប្រើប្រាស់នៅក្នុងរយៈពេល៥ឆ្នាំ។ ដីកាគឺជាប្រភេទលិខិតគតិយុត្តិដែលមានឋានានុក្រមខ្ពស់ជាងគេ សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើសេចក្តីសម្រេច ដើម្បីការងារផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុង

| | |
|---|---|
| ដីកា | 9,451 |
| ចំនួនសេចក្តីសម្រេច | 41,266 |
| លិខិតផ្សេងៗ | 471,514 |

ដែនសមត្ថកិច្ចរបស់ខ្លួន។ នាពេលបច្ចុប្បន្ន កម្រិតយល់ដឹងឱ្យបានស៊ីជម្រៅលើខ្លឹមសារដីកា ភាពខុសគ្នារវាងដីកា និងសេចក្តីសម្រេចនៅមានតែកម្រិតទាប។ ក្រសួងមហាផ្ទៃបានដាក់ចេញឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងបានណែនាំកិច្ចការរដ្ឋបាលចាប់តាំងពីឆ្នាំ ២០០៥ មកម្លេះ។

### ១.១.៧. ការគ្រប់គ្រងទ្រព្យសម្បត្តិឃុំ សង្កាត់

ទ្រព្យសម្បត្តិឃុំ សង្កាត់សំដៅយកសម្ភារៈបរិក្ខារ អគារ រួមទាំងដីធ្លីទាំងឡាយណាដែលជាកម្មសិទ្ធិរបស់ឃុំ សង្កាត់ តាមរយៈការទិញ ឬជំនួយពីសប្បុរសជន និងដៃគូអភិវឌ្ឍន៍នានា។ ទ្រព្យសម្បត្តិទាំងនេះ ឃុំ សង្កាត់ត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌប្រចាំឆ្នាំ។ គេសង្កេតឃើញថា ទ្រព្យសម្បត្តិឃុំ សង្កាត់មានសរុបចំនួន ២៧៦៤០ មុខរបស់ ដែលជាមធ្យមឃុំ សង្កាត់នីមួយៗ មានទ្រព្យសម្បត្តិចំនួនត្រឹម ១៧ មុខរបស់។

### ១.១.៨. ការសម្រុះសម្រួលទំនាស់

ឃុំ សង្កាត់ត្រូវបានផ្តល់ជូននូវសមត្ថកិច្ចក្នុងការជួយសម្រុះសម្រួលនូវរាល់ករណីទំនាស់ដែលមានលក្ខណៈឯកជន រវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ដែលកើតមានឡើងនៅក្នុងឃុំ សង្កាត់។

| | | |
|---|---|---|
| ករណីដែលឃុំ សង្កាត់បានដោះស្រាយ | 124,681 | 92% |
| ករណីដែលបានបញ្ជូនទៅថ្នាក់លើ | 11,126 | 08% |

ជាមធ្យមឃុំ សង្កាត់នីមួយៗ នៅទូទាំងប្រទេសទទួលបានប្រហែល ១៧ពាក្យបណ្តឹងប្រចាំឆ្នាំ ហើយដែលភាគច្រើនបណ្តឹង (៩២ %) ត្រូវបានសម្រុះសម្រួលនៅថ្នាក់ឃុំ សង្កាត់។ លទ្ធផលនេះ បង្ហាញថាប្រជាពលរដ្ឋមានជំនឿកាន់តែរឹងមាំចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការសម្រុះសម្រួលទំនាស់នៅមូលដ្ឋាន ដែលរួមចំណែកកាត់បន្ថយពេលវេលា និងប្រាក់កាសរបស់ប្រជាពលរដ្ឋលើការតវ៉ាក្តីក្តាំងតាមប្រព័ន្ធតុលាការ។

## ១.២ ការអនុវត្តមុខងារជាភ្នាក់ងារ

### ១.២.១. អត្រានុកូលដ្ឋាន

កិច្ចការអត្រានុកូលដ្ឋានគឺជាការអនុវត្តតួនាទីជាភ្នាក់ងាររបស់ឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលខុសត្រូវការងារអត្រានុកូលដ្ឋានក្នុងដែនដីឃុំ សង្កាត់ដែលខ្លួនគ្រប់គ្រង ហើយបានអនុវត្តកិច្ចការនេះជាប្រចាំនៅថ្នាក់មូលដ្ឋាន។ មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន ដែលមានតួនាទីចេញសំបុត្រ អត្រានុកូលដ្ឋានគ្រប់ប្រភេទដល់ប្រជាពលរដ្ឋ។ ជាលទ្ធផល នៅក្នុងអាណត្តិទី២ ឃុំ សង្កាត់បានចុះបញ្ជីអត្រានុកូលដ្ឋាន គួរឱ្យកត់សម្គាល់ ដែលបង្ហាញថាប្រជាពលរដ្ឋកាន់តែយល់ដឹងច្រើនដូចបង្ហាញជូនក្នុងតារាងខាងលើ។

| | |
|---|---|
| ប្រជាពលរដ្ឋសរុបក្នុងឃុំ សង្កាត់ | 14,171,243 |
| ចំនួនសបុត្រកំណើត | 707,209 |
| ចំនួនសំបុត្របញ្ជាក់កំណើត | 1,710,109 |
| ចំនួនសំបុត្រអាពាហ៍ពិពាហ៍ | 190,364 |
| ចំនួនសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | 21,124 |
| ចំនួនសំបុត្របញ្ជាក់មរណភាព | 82,441 |
| ចំនួនសំបុត្របញ្ជាក់មរណភាព | 5,664 |

### ១.២.២. ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

យោងតាមលទ្ធផលវាយតម្លៃបានបង្ហាញថា ប្រជាពលរដ្ឋជាស្ត្រីដែលមានអាយុចាប់ពី១៨ឆ្នាំឡើង មានចំនួន ៩១១៥៣២០នាក់ (ស្មើ៧៤%) បានចុះឈ្មោះបោះឆ្នោត។ ឃុំ សង្កាត់ជាភ្នាក់ងារចុះឈ្មោះ និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតជារៀងរាល់ឆ្នាំសម្រាប់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ ឡើង មានកាតព្វកិច្ចចូលរួមបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួននៅថ្នាក់ឃុំ សង្កាត់ រៀងរាល់អាណត្តិក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ និងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។

| | | |
|---|---|---|
| ចំនួនប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើង | 9,115,320 | 74% |
| ចំនួនប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងជាស្ត្រី | 4,739,262 | 49% |
| សរុបប្រជាពលរដ្ឋទាំង២ភេទដែលបានចុះឈ្មោះបោះឆ្នោត | 8,366,655 | 76% |
| ប្រជាពលរដ្ឋជាស្ត្រីដែលបានចុះឈ្មោះបោះឆ្នោត | 4,109,400 | 56% |
| ប្រជាពលរដ្ឋដែលលប់ឈ្មោះចេញពីបញ្ជីបោះឆ្នោត | 366,625 | 9% |

### ១.៣. ការអនុវត្តផែនការ និងកម្មវិធីវិនិយោគ

គម្រោងអនុវត្តដោយឃុំ សង្កាត់គឺជាគម្រោងដែលប្រើប្រាស់ថវិកាស្ថិតក្នុងផែនការ និងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ រួមមានមូលនិធិឃុំ សង្កាត់ និងថវិកាផ្សេងទៀតដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ ឬ សប្បុរសជននានា។ ការកសាងផែនការនៅថ្នាក់ឃុំ សង្កាត់ត្រូវបានអនុវត្តតាមជំហាន និងដំណាក់កាលជាច្រើនដែលក្នុងនោះ សកម្មភាពប្រជុំតាមភូមិគឺជាសកម្មភាពពុំអាចខ្វះបានក្នុងការកំណត់អាទិភាព និងតម្រូវការរបស់ប្រជាពលរដ្ឋជាក់ស្តែង។ គិតជាមធ្យមនៅទូទាំងប្រទេសឃុំ សង្កាត់នីមួយៗ អាចមានគម្រោងអនុវត្តប្រហែល ២ ទៅ៣គម្រោង ឬកិច្ចសន្យាដែលបានអនុវត្តរៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០០៧ រហូតដល់២០១១។ ក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ ការគាំទ្រគម្រោងឃុំ សង្កាត់ ពុំសូវមានការកើនឡើងច្រើនពីមួយឆ្នាំទៅមួយឆ្នាំនោះទេ ចំណែកគម្រោងគាំទ្រដោយមន្ទីរវិស័យមានការកើនឡើងទ្វេដងជាពិសេសនៅឆ្នាំ២០១១។

| ឆ្នាំ | ឃុំ សង្កាត់ | មន្ទីរវិស័យ | អង្គការ | ផ្សេងៗ | សរុប |
|---|---|---|---|---|---|
| ២០០៧ | 4,336 | 8,609 | 7,019 | 1,405 | 21,369 |
| ២០០៨ | 4,815 | 9,418 | 7,375 | 1,820 | 23,428 |
| ២០០៩ | 5,184 | 10,596 | 9,434 | 2,000 | 27,214 |
| ២០១០ | 2,459 | 9,979 | 10,985 | 2,264 | 25,687 |
| ២០១១ | 5,399 | 10,255 | 53,037 | 2,371 | 71,062 |
| | | | | | |

ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ត្រូវបានទទួលភាគច្រើនផ្តោតលើការសាងសង់ផ្លូវ ស្ពាន សាលារៀន ដែលជាប្រភេទហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៅជនបទ។ ក្រៅពីនោះ ការផ្តល់សេវាកម្មបែបអរូបវន្តមានបរិមាណតិចតួច។ យោងតាមក្រាភិចខាងលើបង្ហាញថា គម្រោងអភិវឌ្ឍន៍ភាគច្រើនគឺត្រូវបានគាំទ្រអនុវត្តដោយអង្គការសង្គមស៊ីវិល និងមន្ទីរជំនាញ។



## ១.៤. ការអនុវត្តថវិកាឃុំ សង្កាត់

### ១.៤.១. មូលនិធិឃុំ សង្កាត់

ក្នុងអាណត្តិទី២ ឃុំ សង្កាត់ត្រូវបានទទួលថវិកាវិភាជន៍ពីរាជរដ្ឋាភិបាលជាមធ្យមត្រឹមប្រហាក់ប្រហែល ៦៣ទៅ១២០លានរៀលក្នុងមួយឆ្នាំ។ ការវិភាជន៍ថវិកាឃុំ សង្កាត់ត្រូវបានកំណត់តាមរយៈរូបមន្តគណនាសមស្របមួយដែលប្រែប្រួលទៅតាមសូចនករដូចជា ចំនួនប្រជាពលរដ្ឋជាក់ស្តែង ឬភាពក្រីក្រជាដើម។ ទំហំថវិការយៈពេល៥ឆ្នាំនេះ មានការកើនឡើងតិចតួចដែលគិតជាមធ្យមស្មើ២,៦% (ផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍)ហើយឃុំ សង្កាត់ភាគច្រើននៅមានការខ្វះខាតក្នុងការឆ្លើយតបទៅតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។

| សរុបថវិកាឃុំ សង្កាត់ទទួលបានប្រចាំឆ្នាំ | | | |
|---|---|---|---|
| ឆ្នាំ | ផ្នែករដ្ឋបាល | ផ្នែកអភិវឌ្ឍន៍ | សរុប |
| 2007 | 36,233,458,217 | 65,555,971,508 | 101,789,429,725 |
| 2008 | 36,187,355,339 | 74,538,079,759 | 110,725,435,098 |
| 2009 | 44,992,947,502 | 91,797,477,687 | 136,790,425,189 |
| 2010 | 50,751,046,560 | 121,657,982,302 | 172,409,028,862 |
| 2011 | 59,517,408,847 | 134,600,463,675 | 194,117,872,522 |
| សរុប | 227,682,216,465 | 488,149,974,931 | 715,832,191,396 |

| ឆ្នាំ | ផ្នែករដ្ឋបាល | ផ្នែកអភិវឌ្ឍន៍ |
|---|---|---|
| 2007 | 36% | 64% |
| 2008 | 33% | 67% |
| 2009 | 33% | 67% |
| 2010 | 29% | 71% |
| 2011 | 31% | 69% |
| សរុប | **39%** | **61%** |

ពិនិត្យមើលថវិកាទាំងនោះត្រូវបានបែងចែកជាពីរផ្នែក គឺទី១ផ្នែករដ្ឋបាល និងទី២ផ្នែកអភិវឌ្ឍន៍។ បើយើងប្រៀបធៀបថវិកាផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍នោះ គិតជាមធ្យមការវិភាជន៍ ថវិកាផ្នែករដ្ឋបាលក្នុងរយៈពេល៥ឆ្នាំអាណត្តិទី២ ស្មើ ៣៩% ចំណែកឯថវិកាផ្នែកអភិវឌ្ឍន៍មានត្រឹម ៦១%។

### ១.៤.២. ការចំណាយរបស់ឃុំ សង្កាត់

ការចំណាយរបស់ឃុំ សង្កាត់ត្រូវបានគណនាសម្រាប់ផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍។ ទន្ទឹមគ្នានេះ ថវិកាវិភាជន៍ផ្នែករដ្ឋបាល និងអភិវឌ្ឍន៍ខាងលើត្រូវបានសន្មតថាជាប្រភព ចំណូលដ៏សំខាន់របស់ឃុំ សង្កាត់ដែលនៅក្នុងនោះ បើយើងធ្វើការប្រៀបធៀបរវាងការចំណូល និងចំណាយឃើញថា ជាមធ្យមការចំណាយរបស់ឃុំ សង្កាត់រយៈពេល៥ឆ្នាំ ត្រឹមចំនួន ៨៦% តែប៉ុណ្ណោះ។ ដោយឡែក លទ្ធភាពចំណាយរបស់ឃុំ សង្កាត់នៅឆ្នាំ ២០១០ មានត្រឹមតែ ៧៧ % ដែលចំនួននេះទាបជាងបណ្តាឆ្នាំផ្សេងៗទៀត។



### ១.៤.៣. ការប្រមូលទុនបដិភាគ

ការប្រមូលទុនបដិភាគពីប្រជាពលរដ្ឋត្រូវបានអនុវត្តជារៀងរាល់ឆ្នាំ ក្នុងគោលបំណងចូលរួមការទទួលខុសត្រូវ និងពង្រឹងភាពជាម្ចាស់នៃការអនុវត្តគម្រោង។ គោលការណ៍នៃការប្រមូលទុនបដិភាគ ត្រូវបានកំណត់នៅក្នុងសៀវភៅណែនាំការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ដែលគណៈកម្មាធិការគ្រប់គ្រងគម្រោងមានតួនាទីកំណត់បរិមាណទុនចូលរួមពីប្រជាពលរដ្ឋរបស់ខ្លួនតាមភូមិនីមួយៗ។ នៅក្នុងការរៀបចំកិច្ចសន្យាអនុវត្តគម្រោងឃុំ សង្កាត់ត្រូវពិនិត្យ និងសម្រេចថាតើទុនចូលរួមពីប្រជាពលរដ្ឋចំនួនប៉ុន្មាន នឹងត្រូវប្រមូលពីប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋដែលមានមូលដ្ឋាននៅភូមិដែលទីតាំងគម្រោងត្រូវអនុវត្ត។ យោងតាមលទ្ធផល នៃក្រាភិចនេះបង្ហាញថា លទ្ធភាពប្រមូលទុនបដិភាគពីប្រជាពលរដ្ឋ មានការកើនឡើងជាលំដាប់បើប្រៀបធៀបផែនការប្រមូលទុនបដិភាគតាមបណ្តាឆ្នាំអនុវត្តគម្រោងនីមួយៗ។ គិតជាមធ្យមភាគការប្រមូលទុនចូលរួមបាន៨៣% នៅទូទាំងប្រទេសនៃរយៈពេល ៥ឆ្នាំ កន្លងមកនេះ។ ប្រជាពលរដ្ឋ ត្រូវបានប្រគល់បង្កាន់ដៃទទួលប្រាក់របស់ខ្លួននៅពេលពួកគាត់បានបង់ថវិកាចូលរួមទុនបដិភាគចំណែកថវិកាទាំងអស់ដែលឃុំ សង្កាត់ប្រមូលបានត្រូវដាក់បញ្ចូលចូលគណនីរបស់ឃុំ សង្កាត់ សម្រាប់ទូទាត់ការចំណាយអភិវឌ្ឍន៍គម្រោង។




## ១.៥. ការកសាងសមត្ថភាពឃុំ សង្កាត់

### ១.៥.១. ការបណ្តុះបណ្តាល

ការពង្រឹងសមត្ថភាពគឺជាសកម្មភាពអាទិភាពដែលត្រូវបានយកចិត្តទុកដាក់ និងអនុវត្តដើម្បីបង្កើនចំណេះដឹងដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានតែងតែសហការរៀបចំការសិក្សាអំពីតម្រូវការ និងជំនាញរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន ព្រមទាំងរៀបចំការបណ្តុះបណ្តាលជារៀងរាល់ឆ្នាំ។ យុទ្ធសាស្ត្រ នៃការបណ្តុះបណ្តាលត្រូវបានអនុវត្ត តាមរយៈការបណ្តុះបណ្តាលគ្រូឧទេសថ្នាក់ជាតិ រាជធានី ខេត្ត និងបន្តដល់ក្រុង ស្រុក ខណ្ឌ។ ក្រៅពីនេះ ការបណ្តុះបណ្តាល ឬសិក្ខាសាលាផ្សេងៗ ត្រូវបានរៀបចំដោយមន្ទីរ អង្គភាព និងអង្គការសមាគមដែលអនុវត្តការងារពាក់ព័ន្ធវិមជ្ឈការ។ ជាទូទៅ ចំនួនវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាដែលក្រុមប្រឹក្សាឃុំ សង្កាត់បានចូលរួមមានចំនួនជាមធ្យម ៥៨៨០ លើកក្នុងមួយឆ្នាំ។



### ១.៥.២. ទស្សនកិច្ចសិក្សា

ទស្សនកិច្ចសិក្សាសំដៅការផ្តល់ឱកាសឱ្យក្រុមប្រឹក្សាឃុំ សង្កាត់បានចូលរួមរៀនសូត្រស្វែងយល់ពីបទពិសោធន៍ ជំនាញ ចំណេះដឹងនានា ដែលមានការគាំទ្រពីរដ្ឋាភិបាល អង្គភាពពាក់ព័ន្ធ និងអង្គការសម្រាប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងនៅក្នុងស្រុក និងក្រៅប្រទេស។ នៅក្នុងរយៈពេល ០៥ឆ្នាំ




អាណត្តិទី២នេះ ការគាំទ្រសកម្មភាពទស្សនកិច្ចសិក្សាដល់ក្រុមប្រឹក្សាឃុំ សង្កាត់នៅមានកម្រិតទាប យើងសង្កេតឃើញជាមធ្យមមានតែ៣លើកប៉ុណ្ណោះ ដែលឃុំ សង្កាត់នីមួយៗទទួលបានទស្សនកិច្ចសិក្សា។ ប៉ុន្តែចំនួនទស្សនកិច្ចមានការកើនឡើងជាលំដាប់ចាប់តាំងពីឆ្នាំ២០១០មក។

### ១.៥.៣. ការចុះគាំទ្រ និងអន្តរាគមន៍ដល់ឃុំ សង្កាត់

រដ្ឋបាលក្រុង ស្រុក មានភារកិច្ច ចំបងក្នុងការចុះជួយគាំទ្រដល់ឃុំ សង្កាត់ជាពិសេសកិច្ចការពាក់ព័ន្ធកសាងផែនការ និងអនុវត្តគម្រោងដែលប្រើប្រាស់មូលនិធិឃុំសង្កាត់។ ក្រៅពីនោះថ្នាក់ខេត្ត ក៏ត្រូវផ្តល់ការគាំទ្រដល់មូលដ្ឋានទៀតផង។ យោងតាមរបាយការណ៍ ចុះគាំទ្រនិងអន្តរាគមន៍ដល់ឃុំ សង្កាត់បង្ហាញថាជាមធ្យមមាន ចំនួន៧លើកក្នុងខែនីមួយៗដែលឃុំ សង្កាត់បានទទួលការចុះគាំទ្រ និងអន្តរាគមន៍ពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ស្ថាប័ន អង្គការ




សង្គមស៊ីវិលជាដើម។ ជាទូទៅ សកម្មភាពចុះគាំទ្រ និងអន្តរាគមន៍ ពុំសូវមានការប្រែប្រួលកើន ឬថយនោះទេចាប់តាំងពីឆ្នាំ ២០០៧ មកម្លេះ។

## ២. ប្រសិទ្ធភាពនៃកិច្ចអភិបាល ការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវាកម្មឃុំ សង្កាត់

ប្រសិទ្ធិភាពនៃការអនុវត្តការងាររបស់ឃុំ សង្កាត់ ត្រូវបានវាស់វែងតាមរយៈការផ្តល់ឱកាសឱ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងអ្នកទទួលបន្ទុកស្ត្រី និងកុមារឃុំ សង្កាត់សាមីវាយតម្លៃ ដាក់ពិន្ទុលើបញ្ជីសំណួរដែលបានរៀបចំតាមលំដាប់លំដោយ រួមមានផ្នែកគ្រប់គ្រងរដ្ឋបាល ការអនុវត្តមុខងារភ្នាក់ងារ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងមូលនិធិឃុំ សង្កាត់ ការពង្រឹងសមត្ថភាព និងកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។ ទន្ទឹមគ្នានេះ ប្រជាពលរដ្ឋតាមភូមិគោលដៅក៏ត្រូវបានជ្រើសរើសជាក្រុមគោលដៅ ក្នុងការផ្តល់យោបល់លើការអនុវត្តកិច្ចការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រៅពីនោះ សមាគមមូលដ្ឋានត្រូវបានជ្រើសរើសតាមឃុំ សង្កាត់ ក្នុងការផ្តល់ព័ត៌មានត្រឡប់មកក្រុមប្រឹក្សាឃុំ សង្កាត់ ។

ខាងក្រោមនេះ ជាការរៀបរាប់ដោយសង្ខេបនូវលទ្ធផលបូកសរុបចម្លើយដែលរាជធានី ខេត្តបានផ្តល់របាយការណ៍ស្តីពីការវាយតម្លៃកិច្ចការផ្ទៃក្នុងឃុំ សង្កាត់សម្រាប់អាណត្តិទី២។

## ២.១. ការគ្រប់គ្រងរដ្ឋបាល

### ២.១.១. កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

| កិច្ចប្រជុំប្រចាំខែក្រុមប្រឹក្សាឃុំ សង្កាត់ (សំណួរទី ០១-០៧) | | | |
|---|---|---|---|
| មិនដឹង | ពី១-៤ លើក | ពី៥-៧ លើក | ពី៨-១០ លើក |
| 5% | 15% | 26% | 53% |

លទ្ធផលបង្ហាញថា ៥៣ %នៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ យល់ឃើញថា ជាទូទៅពួកគាត់គិតថាបានទទួលលិខិតអញ្ជើញ និងរបៀបវារៈអំពីកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ១០ លើកចុងក្រោយ ក៏ប៉ុន្តែការផ្សព្វផ្សាយអំពីពេលវេលា ទីកន្លែង និងរបៀបវារៈដល់ប្រជាពលរដ្ឋ ការចូលរួមរបស់ប្រជាពលរដ្ឋ និងការបិទផ្សាយលទ្ធផលកិច្ចប្រជុំ នៅមានកម្រិតទាបជាង ៤០ %។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់យល់ឯកភាពលើសារៈសំខាន់នៃការរៀបចំកិច្ចប្រជុំ ហើយកិច្ចប្រជុំប្រចាំខែតែងតែមានកំណត់ហេតុ។ ចំណែកប្រជាពលរដ្ឋភាគច្រើន (៤៦%) ឆ្លើយថា ពួកគាត់ម្តងម្កាលបានដឹងពីកិច្ចប្រជុំ ប្រចាំខែ ចូលរួម កិច្ចប្រជុំ និងមានឱកាសផ្តល់យោបល់ក្នុងកិច្ចប្រជុំ។

### ២.១.២. ការផ្ទេរសិទ្ធិ

| ការងារផ្ទេរសិទ្ធិរបស់មេឃុំ ចៅសង្កាត់ (សំណួរទី ០៩-១០) | | | |
|---|---|---|---|
| មិនដឹង | មិនបានល្អ | មធ្យម | ល្អ |
| 3% | 10% | 41% | 47% |

ជាទូទៅ ស្ទើរពាក់កណ្តាល(៤៧ %)នៃសមាជិកក្រុមប្រឹក្សាយល់ថា ការផ្ទេរសិទ្ធិរបស់មេឃុំ ចៅសង្កាត់ នាពេលកន្លងបានល្អ ព្រមទាំងការអនុវត្តតួនាទី ភារកិច្ចរបស់អ្នកដែលទទួលបានការផ្ទេរសិទ្ធិក៏បានសមស្របផងដែរ។ ចំណែកឯសមាជិក ៤១ % ទៀតបានគិតថាការផ្ទេរសិទ្ធិនៅមានកម្រិតនៅឡើយ។

### ២.១.៣. លិខិតចេញ-ចូល

| ការងារលិខិតស្នាមចេញ-ចូល (សំណួរទី ១២-១៣) | | | |
|---|---|---|---|
| មិនដឹង | មិនបានល្អ(មិនស្រប) | មធ្យម(បានល្អបង្គួរ) | ល្អ(សមស្រប) |
| 3% | 6% | 39% | 52% |

សមាជិកក្រុមប្រឹក្សាភាគច្រើន ៥២ % យល់ឃើញថា ការចាត់ចែងលិខិតរបស់ឃុំ សង្កាត់ បានសមស្របតាមការណែនាំ និងនីតិវិធី ក្រៅពីនោះ ៣៩ %គិតថាការចាត់ចែងលិខិតចេញចូលនៅមានកម្រិតមធ្យម។ ចំណែកឯដីកា និងសេចក្តីសម្រេច ក៏ក្រុមប្រឹក្សាឃុំ សង្កាត់ភាគច្រើនទទួលយល់ស្របថា បានរៀបចំតាមនីតិវិធី។

២.១.៤. ការគ្រប់គ្រងទ្រព្យសម្បត្តិឃុំ សង្កាត់

| ការគ្រប់គ្រងទ្រព្យសម្បត្តិឃុំ សង្កាត់ (សំណួរទី ១៥-១៧) | | | |
|---|---|---|---|
| មិនដឹង | មិនដែល(មិនបានល្អ) | មានខ្លះ(មធ្យម) | មានច្បាស់លាស់(ល្អ) |
| 2% | 7% | 36% | 55% |

ភាគច្រើននៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ៥៥ % យល់ថា ទ្រព្យសម្បត្តិឃុំ សង្កាត់ ត្រូវបានចាត់ចែងបានច្បាស់លាស់តាមរយៈការធ្វើបច្ចុប្បន្នភាពបញ្ជីទ្រព្យសម្បត្តិ។ ចំណែក៣៦ % ផ្សេងទៀតយល់ថា ការប្រើប្រាស់ទ្រព្យសម្បត្តិ និងការថែរទាំទ្រព្យសម្បត្តិ បានកម្រិតមធ្យម ។

២.១.៥. ការប្រមូល និងការប្រើប្រាស់ទិន្នន័យ

| ការប្រមូល និងការប្រើប្រាស់ទិន្នន័យ (សំណួរទី ១៩-២២) | | | |
|---|---|---|---|
| មិនដឹង | មិនមានប្រយោជន៍(មិនមាន) | តិចតួច(មធ្យម) | មានប្រយោជន៍ណាស់(មានច្រើន) |
| 1% | 4% | 27% | 67% |

ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំ សង្កាត់ភាគច្រើនត្រូវបានឃុំ សង្កាត់យល់ឃើញថាមានសារៈប្រយោជន៍ និងបានសហការជាមួយស្ថាប័ន មន្ទីរវិស័យក្នុងការប្រមូលព័ត៌មាន។ លើសពីនេះឯកសារព័ត៌មានបានបម្រើផលប្រយោជន៍ឃុំ សង្កាត់ក្នុងការកសាងផែនការ។ ទោះជាយ៉ាងណា សុក្រិតភាពនៃការប្រមូលទិន្នន័យនៅពុំទាន់បានឯកភាពគ្នាខ្ពស់នៅឡើយ។

២.១.៦. ការគ្រប់គ្រងឯកសារ

| ការគ្រប់គ្រងឯកសារ (សំណួរទី ២៤-២៦) | | | |
|---|---|---|---|
| មិនដឹង | មិនសមស្រប(មិនងាយ) | ល្អ ង្គួរ(ងាយដែរ) | ងាយណាស់(សមស្រប) |
| 1% | 8% | 51% | 40% |

ការរៀបចំទុកដាក់ឯកសាររបស់ឃុំ សង្កាត់នៅមានកម្រិតនៅឡើយ ព្រោះសមាជិកដែលយល់ឃើញដូច្នេះមានត្រឹមតែ៤០% ប៉ុណ្ណោះ ក្នុងនោះការគ្រប់គ្រងសំដៅលើការថែរទាំ និងទុកដាក់ឯកសារ ហើយសមាជិកក្រុមប្រឹក្សា និងបុគ្គលិក តែងតែងាយស្រួលក្នុងការយកប្រើប្រាស់ឯកសារ។

២.១.៧. ការទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មាន

| ការទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មាន (សំណួរទី ២៨-៣០) | | | |
|---|---|---|---|
| មិនដឹង | មិនបាន(ខ្សោយ) | បានខ្លះៗ(មធ្យម) | បានល្អ(បានសមស្រប) |
| 1% | 6% | 51% | 43% |

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់៤៣ % បានយល់ឃើញថា ការផ្សព្វផ្សាយព័ត៌មានដល់ប្រជា-ពលរដ្ឋក្នុងឃុំ សង្កាត់មានកម្រិតល្អដែលអាចធ្វើឱ្យប្រជាពលរដ្ឋងាយស្រួលយល់ដឹងអំពីខ្លឹមសារនៃព័ត៌មាន និងចូលរួមរបស់ពួកគាត់។

២.១.៨. ការរៀបចំរបាយការណ៍ប្រចាំខែ និងឆ្នាំ

| ការរៀបចំរបាយការណ៍ប្រចាំខែ និងឆ្នាំ (សំណួរទី ៣២) | | | |
|---|---|---|---|
| មិនដឹង | មិនទៀងទាត់ | យឺតម្តងម្កាល | ទៀងទាត់ |
| 1% | 8% | 48% | 43% |

កន្លងមករបាយការណ៍ឃុំ សង្កាត់ត្រូវបានកំណត់ឱ្យរៀបចំប្រចាំខែ និងឆ្នាំ តាមទម្រង់ដែលបានណែនាំ។ ៤៨ % នៃអ្នកផ្តល់ចម្លើយយល់ឃើញថា ការរៀបចំរបាយការណ៍ឃុំ សង្កាត់មានការយឺតយ៉ាវម្តងម្កាល ចំណែក ៤៣% ទៀតយល់ស្របថាការរៀបចំរបាយការណ៍បានទៀងទាត់។

២.១.៩. ការផ្តល់សេវាកម្មផ្សេងរបស់ឃុំ សង្កាត់

| ការផ្តល់សេវាកម្មផ្សេងរបស់ឃុំ សង្កាត់ (សំណួរទី ៣៤-៣៥) | | | |
|---|---|---|---|
| មិនដឹង | មិនល្អ(ខ្សោយ) | បង្គួរ(មធ្យម) | ល្អ(ល្អណាស់) |
| 1% | 8% | 60% | 31% |

ជាចំបងការផ្តល់សេវាកម្មរបស់ក្រុមប្រឹក្សាឃុំ សង្កាត់សំដៅយកការសម្រុះសម្រួលទំនាស់ ដែលប្រជាពលរដ្ឋបានរាយការណ៍ ឬដាក់ពាក្យបណ្តឹង រួមទាំងកិច្ចការសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ក្នុងឃុំ សង្កាត់។ ក្នុងន័យនេះ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (៦០ %) បានបញ្ជាក់ការយល់ឃើញថា ការផ្តល់សេវាកម្មរបស់ឃុំ សង្កាត់ មានកម្រិតល្អបង្គួរ និង ៣១ % លើកឡើងថាសេវាកម្មនេះបានផ្តល់កម្រិតល្អណាស់។

២.១.១០. បញ្ហាការពង្រឹងសិទ្ធអំណាចស្ត្រី

| បញ្ហាការពង្រឹងសិទ្ធអំណាចស្ត្រី (សំណួរទី ៣៧-៣៩) | | | |
|---|---|---|---|
| មិនដឹង | ខ្សោយ | មធ្យម | ច្រើន |
| 1% | 7% | 43% | 50% |

លទ្ធផលនៃការបូកសរុបរបាយការណ៍បង្ហាញថា ៥០ % នៃអ្នកផ្តល់ចម្លើយ យល់ឃើញថាក្រុមប្រឹក្សាឃុំ សង្កាត់បានយល់ដឹងនូវការងារយេនឌ័រ ឬការលើកកំពស់ស្ត្រី កុមារ ជនពិការ និងក្រុមជនងាយរងគ្រោះ លើសពីនេះការជួយជ្រោមជ្រែងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី និងការយកចិត្តទុកដាក់ដោះស្រាយអំពីបញ្ហាស្ត្រី។ ដោយឡែក ៤៣ % ទៀត យល់ការយល់ដឹងការងារពង្រឹងសិទ្ធិអំណាចស្ត្រីនៅមានកម្រិតមធ្យមនៅឡើយ។

## ២.២. ការអនុវត្តមុខងារជាផ្លាក់ងារ

២.២.១. អត្រានុកូលដ្ឋាន

| អត្រានុកូលដ្ឋាន (សំណួ រទី ៤១-៤៣) | | | |
|---|---|---|---|
| មិនដឹង | ខ្សោយ(មិនមានប្រយោជន៍) | មធ្យម(មានប្រយោជន៍តិចតួច) | ល្អ(មានប្រយោ.ណាស់) |
| 0% | 7% | 32% | 61% |

ការងារអត្រានុកូលដ្ឋានពាក់ព័ន្ធទៅនឹងការយល់ដឹងអំពីរបៀបចុះបញ្ជីអត្រានុកូលដ្ឋាន និងការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការងារអត្រានុកូលដ្ឋាន ឃុំ សង្កាត់មានការយល់ដឹងច្រើន។ ៦១ % នៃអ្នក

ផ្តល់ចម្លើយយល់ឃើញថាកិច្ចការអត្រានុកូលដ្ឋាន ត្រូវបានឃុំ សង្កាត់អនុវត្តបានល្អត្រឹមត្រូវ។ ទន្ទឹមគ្នានេះ ៣២%យល់ថាការយល់ដឹងត្រឹមកម្រិតមធ្យមតែប៉ុណ្ណោះ។

២.២.២. ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

| ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត (សំណួរទី ៤៥-៤៦) | | | |
|---|---|---|---|
| មិនដឹង | ខ្សោយ | មធ្យម | ល្អ |
| 1% | 6% | 37% | 57% |

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ៥៧ % សំដែងការយល់ដឹងពីដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតទទួលបានលទ្ធផលល្អ និង៣៧ %ប្រជាពលរដ្ឋយល់ដឹងពីដំណើរការធ្វើបច្ចុប្បន្នភាពលើបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោតដែលអនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់មាន កម្រិតមធ្យមតែប៉ុណ្ណោះ។

## ២.៣. ការគ្រប់គ្រងហិរញ្ញវត្ថុ

២.៣.១. ការប្រើប្រាស់មូលនិធិឃុំ សង្កាត់

| ការប្រើប្រាស់មូលនិធិឃុំ សង្កាត់(សំណួ រទី ៤៨-៥៣) | | | |
|---|---|---|---|
| មិនដឹង | មិនបាន | បានខ្លះ | ទៀងទាត់(បានល្អ) |
| 1% | 6% | 31% | 61% |

សមាជិកក្រុមប្រឹក្សាភាគច្រើនលើសលុប (៦១ %)បានជ្រើសរើសយកចម្លើយ ឃ មានន័យថាពួកគេយល់ឃើញថាឃុំ សង្កាត់សាមីបានប្រើប្រាស់ថវិកាឃុំ សង្កាត់នាពេលកន្លងមកចំគោលដៅ មានតម្លាភាព និងការសន្សំសំចៃ ។ ទន្ទឹមគ្នានេះ អ្នកផ្តល់ចម្លើយ(៧ %) បញ្ចេញទស្សនៈ មិនយល់ស្របនោះទេ។

២.៣.២. ការប្រមូលទុនចូលរួមរបស់មូលដ្ឋាន

| ការប្រមូលទុនចូលរួមរបស់មូលដ្ឋាន(សំណួរទី ៥៥-៥៩) | | | |
|---|---|---|---|
| មិនដឹង | មិនបាន | បានខ្លះ(ពេញចិត្តខ្លះ) | បានល្អ(មានតម្លាភាព) |
| 1% | 6% | 32% | 60% |

សូចនករ នៃការប្រមូលទុនចូលរួមរបស់មូលដ្ឋានពាក់ព័ន្ធទៅនឹងការផ្សព្វផ្សាយដំណើរការរៀបចំថវិកា កម្រិតចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកា និងលក្ខណសន្សំសំចៃនៃការរៀបចំថវិកា។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់(៦០%) បានសំដែងការពេញចិត្តចំពោះការប្រមូលទុនចូលរួមរបស់មូលដ្ឋាន។

២.៣.៣. របាយការណ៍ហិរញ្ញវត្ថុ

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់(៤៤ %) យល់ឃើញថារបាយការណ៍ហិរញ្ញវត្ថុប្រចាំខែត្រូវបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ បានដឹងអំពីប្រភពចំណូលផ្សេងៗ ព្រមទាំងស្នើសុំសាច់ប្រាក់ បុរេប្រទានបានទាន់ពេល។ ចំណែក ៣៧% ផ្សេងៗទៀត បានដឹងខ្លះៗ ពីការស្ថានភាពរបាយការណ៍ហិរញ្ញវត្ថុ។

| របាយការណ៍ហិរញ្ញវត្ថុ (សំណួរទី ៦១-៦៥) | | | |
|---|---|---|---|
| មិនដឹង | មិនបាន(មិនមាន) | បានខ្លះៗ(ដឹងច្បាស់) | បានល្អ(ទាន់ជានិច្ច) |
| 5% | 15% | 37% | 44% |

២.៣.៤. ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ច្រើនជាងពាក់កណ្តាល (៦០ %) បានសំដែងភាពពេញចិត្ត ចំពោះដំណើការរៀបចំថវិកាប្រចាំឆ្នាំ ប៉ុន្តែ៣២% ផ្សេងទៀត យល់ឃើញថានៅមានចំណុចខ្វះខាត។

| ការប្រមូលទុនចូលរួមរបស់មូលដ្ឋាន(សំណួរទី ៥៥-៥៨) | | | |
|---|---|---|---|
| មិនដឹង | មិនបាន | បានខ្លះ(ពេញចិត្តខ្លះ) | បានល្អ(មានតម្លាភាព) |
| 1% | 6% | 32% | 60% |

## ២.៤. ការគ្រប់គ្រងគម្រោងមូលនិធិឃុំ សង្កាត់

២.៤.១. ដំណើរការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់

| ដំណើរការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់(សំណួរទី ៧៣-៧៧) | | | |
|---|---|---|---|
| មិនដឹង | មិនធ្លាប់(តិចតួច) | ម្តងម្កាល(មធ្យម) | ជានិច្ច(ល្អ) |
| 3% | 9% | 39% | 50% |

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់(៥០%) យល់ឃើញថាដំណើរការកម្មវិធីវិនិយោគ ត្រូវបានរៀបចំ សមស្របតាមគោលការណ៍ណែនាំ ដូចជាការផ្សព្វផ្សាយកម្មវិធីវិនិយោគដល់ប្រជាពលរដ្ឋ ការចូលរួម របស់ប្រជាពលរដ្ឋក្នុងការកំណត់អាទិភាពតាមភូមិ និងការចាត់អាទិភាពតម្រូវការ និងការប្រើប្រាស់ថវិកា ឆ្លើយតបទៅតម្រូវការទាំងនោះ។ ទោះជាយ៉ាងណា ៣៩ % នៃអ្នកផ្តល់ចម្លើយបានបញ្ចេញទស្សនៈថា ដំណើរការកសាងផែនការនៅមានកម្រិតមធ្យមនៅឡើយ។

២.៤.២. ការសិក្សាលទ្ធភាពគម្រោងឃុំ សង្កាត់

| ការសិក្សាលទ្ធភាពគម្រោងឃុំ សង្កាត់ (សំណួរទី ៧៩-៨១) | | | |
|---|---|---|---|
| មិនដឹង | មិនចូលរួម | ចូលរួមតិចតួច | ចូលរួមពេញលេញ |
| 1% | 5% | 34% | 60% |

ការសិក្សាលទ្ធភាពគម្រោងឃុំ សង្កាត់តម្រូវឱ្យឃុំ សង្កាត់ចូលរួមយ៉ាងសកម្មក្នុងដំណើរការតាម ដំណាក់កាលនីមួយៗ ជាពិសេសការចូលរួមសិក្សាដីធ្លី និងបរិស្ថាន ព្រមទាំងការចូលរួមប្រជាពលរដ្ឋ ផងដែរ។ លទ្ធផលបង្ហាញថាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ៦០ % សំដែងការពេញចិត្តចំពោះដំណើរ ការសិក្សាលទ្ធភាពគម្រោង ចំណែក ៣៤% វិញយល់ថានៅមានការចូលរួមតិចតួចនៅឡើយ។

២.៤.៣. ការអនុវត្តគម្រោងឃុំ សង្កាត់

| ការអនុវត្តគម្រោងឃុំ សង្កាត់ (សំណួរទី ៨៣-៩០) | | | |
|---|---|---|---|
| មិនដឹង | មិនសមស្រប(មិនយល់) | យល់ខ្លះ(មធ្យម) | សមស្រប(ត្រឹមត្រូវ) |
| 2% | 4% | 37% | 58% |

សូចនករនៃការអនុវត្តគម្រោងផ្តោតលើដំណើរការប្រកាសដេញថ្លៃ ការយល់ដឹងអំពីនីតិវិធីដេញថ្លៃ ការបំពេញតួនាទីរបស់គណៈកម្មការដេញថ្លៃ គុណភាពគម្រោងដែលបានអនុវត្ត ភាពពេញចិត្តរបស់ប្រជាពលរដ្ឋ កម្រិតតាមដានលើការអនុវត្តគម្រោងរបស់ឃុំ សង្កាត់។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ៥៨% បានយល់ស្របទៅលើភាពត្រឹមត្រូវនៃការអនុវត្តគម្រោង ដោយឡែក ៣៧ % ផ្សេងទៀត បានយល់ថា ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់មានកម្រិតមធ្យមតែប៉ុណ្ណោះ។

២.៤.៤. ការប្រើប្រាស់ និងថែទាំលទ្ធផលគម្រោង

| ការប្រើប្រាស់ និងថែទាំលទ្ធផលគម្រោង (សំណួរទី ៩២-៩៦) | | | |
|---|---|---|---|
| មិនដឹង | មិនបាន | បានខ្លះ(មានខ្លះ) | មានគ្រប់គ្រាន់(មានច្រើន) |
| 1% | 6% | 39% | 54% |

ការប្រើប្រាស់ និងថែទាំលទ្ធផលគម្រោងត្រូវបានវាស់វែងទៅលើការផ្តល់ផលប្រយោជន៍របស់គម្រោង គណៈកម្មការថែទាំលទ្ធផលគម្រោង ការផ្សព្វផ្សាយ និងចូលរួមរបស់ប្រជាពលរដ្ឋក្នុងការថែទាំសមិទ្ធផលគម្រោង។ លទ្ធផលបង្ហាញថាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ៥៤ % បានដាក់ពិន្ទុខ្ពស់ ដោយសំដែងការពេញចិត្ត ទៅលើការប្រើប្រាស់ និងថែទាំលទ្ធផលគម្រោងរបស់ឃុំ សង្កាត់ ក៏ប៉ុន្តែ៣៩ % ផ្សេងទៀតបានដាក់ពិន្ទុត្រឹមកម្រិតមធ្យម។

## ២.៥. ការពង្រឹងសមត្ថភាពឃុំ សង្កាត់

| ល.រ | វគ្គបណ្តុះបណ្តាល | បានបណ្តុះ. ដែរឬទេ? | | បើបាន តើកើនចំណេះដឹង និងការការអនុវត្តរបស់ខ្លួនកម្រិតណា? | | | | |
|---|---|---|---|---|---|---|---|---|
| | | មិនបាន | បាន | គ្មាន | តិចតួច | មធ្យម | ល្អ | ល្អណាស់ |
| ១ | វគ្គតម្រង់ទិសស្តីពីវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ | 12% | 88% | 4% | 13% | 47% | 32% | 4% |
| ២ | ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ | 9% | 91% | 2% | 9% | 45% | 39% | 5% |
| ៣ | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ | 25% | 75% | 7% | 16% | 44% | 30% | 4% |
| ៤ | ការសិក្សាដីធ្លី និងផលប៉ះពាល់បរិស្ថាន | 20% | 80% | 5% | 15% | 43% | 33% | 5% |
| ៥ | ការចូលរួមរបស់ជនជាតិដើមភាពតិចក្នុងដំណើរការកសាងផែនការ | 31% | 43% | 24% | 16% | 33% | 22% | 5% |
| ៦ | ការអនុវត្តគម្រោងមូលធិនិឃុំ សង្កាត់ | 14% | 88% | 3% | 11% | 44% | 37% | 5% |
| ៧ | ការតាមដាន និងវាយតម្លៃ | 14% | 82% | 5% | 11% | 44% | 36% | 5% |
| ៨ | អត្រានុកូលដ្ឋាន | 24% | 76% | 7% | 9% | 37% | 36% | 7% |
| ៩ | កិច្ចការរដ្ឋបាល | 20% | 80% | 5% | 12% | 43% | 33% | 5% |
| ១០ | អភិបាលកិច្ចល្អ | 17% | 83% | 5% | 12% | 46% | 30% | 5% |
| **សរុប** | | **18%** | **81%** | **6%** | **12%** | **43%** | **33%** | **5%** |

ជាទូទៅ សមាជិកក្រុមប្រឹក្សា (៨១%) យល់ថាពួកគាត់បានទទួលការបណ្តុះបណ្តាលនូវវគ្គសំខាន់ៗដូចបានបង្ហាញជូននៅក្នុងតារាងខាងលើ ទោះជាយ៉ាងណាក៏មានសមាជិកក្រុមប្រឹក្សា(១៩%) បានបដិសេធមិនបានគិតថាវគ្គទាំងនោះត្រូវបានរៀបចំបណ្តុះបណ្តាលឡើយ។ ចំណែកលទ្ធផលវិញ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ៥៣ % ទទួលបានចំណេះដឹងកើន កម្រិតមធ្យម និង ៣៣ % ទទួលបានចំណេះដឹងកម្រិតល្អ ចំណែកឯ ១២% ទទួលយល់ឃើញថាពួកគេទទួលបានចំណេះដឹងតិចតួចនៅឡើយ។

## ២.៦. កិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ

ក្រុមប្រឹក្សាឃុំ សង្កាត់បានផ្តល់ការវាយតម្លៃ ដោយដាក់ពិន្ទុលើកិច្ចសហការជាមួយស្ថាប័នគាំទ្រថ្នាក់ខេត្ត ក្រុង ស្រុក អង្គភាពពាក់ព័ន្ធ និងអង្គការនានា។ លទ្ធផលបង្ហាញថា ក្រុមប្រឹក្សាឃុំ សង្កាត់ ៣៥% យល់ថាស្ថាប័នពាក់ព័ន្ធបានចុះគាំទ្រពេញលេញ។ ចំណែក ៣៣ % ឆ្លើយថា កម្រិតល្អបង្គួរ និង៧ % តែប៉ុណ្ណោះ ដែលយល់ថារាជធានី ខេត្ត ក្រុង ស្រុក និង អង្គភាពពាក់ព័ន្ធទទួលបានការគាំទ្រត្រឹមតិចតួច។

| លក្ខណវិនិច្ឆ័យ | សរុបអ្នកផ្តល់ចម្លើយ | ភាគរយ |
|---|---|---|
| ១-គ្មានសោះ | 7163 | 4% |
| ២-តិចតួច | 13654 | 7% |
| ៣-គ្រប់គ្រាន់ | 38101 | 21% |
| ៤-ល្អបង្គួរ | 61042 | 33% |
| ៥-ល្អប្រសើរ | 63463 | 35% |
| សរុប | 183424 | 100% |

# ផ្នែកទី III
# អនុសាសន៍គោលម្អ

## ផ្នែកទី III
## អនុសាសន៍គោលម្ភ

### ១. ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

### ១.១ ការប្រជុំប្រចាំខែ

- ត្រូវប្រជុំប្រចាំខែអោយបានទៀងទាត់ មានលិខិតអញ្ជើញដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អោយបានយ៉ាងហោចណាស់បីថ្ងៃមុន និងភ្ជាប់របៀបវារៈប្រជុំឱ្យបានច្បាស់លាស់
- ត្រូវកំណត់កាលបរិច្ឆេទប្រជុំប្រចាំខែឱ្យបានជាក់លាក់រួចចម្លងជូនថ្នាក់ខេត្ត និងស្ថាប័នពាក់ព័ន្ធ ដើម្បីកុំឱ្យជាន់កម្មវិធីគ្នា
- ក្រុមប្រឹក្សាឃុំ សង្កាត់ គួរខិតខំស្វែងយល់ឱ្យបានស៊ីជម្រៅអំពីច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងអនុវត្តឱ្យបានទៀងទាត់នូវបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្តីអំពីការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា
- លទ្ធផលនៃការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការផ្សព្វផ្សាយ ឱ្យបានទូលំទូលាយ ដល់គ្រប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងដល់ប្រជាពលរដ្ឋមូលដ្ឋានផងដែរ។ លើសពីនេះ ត្រូវជម្រុញលើកទឹកចិត្តឱ្យស្ត្រី និងក្រុមងាយរងគ្រោះបានលើកបញ្ហាតម្រូវការពួកគាត់ បានចូលរួមលើកមតិយោបល់ក្នុងពេលប្រជុំ
- កិច្ចប្រជុំក្រុមប្រឹក្សាប្រចាំខែ គួរចល័តការប្រជុំតាមភូមិ (ឧ.ខែមករា ភូមិ "ក" ខែកុម្ភៈឃុំ "ខ") ដើម្បីងាយស្រួលដល់ប្រជាពលរដ្ឋចូលរួម
- ត្រូវអញ្ជើញជនបង្គោល តំណាងសហគមន៍ (CBO) អ្នកពាក់ព័ន្ធផ្សេងៗ និងប្រជាពលរដ្ឋចាស់ព្រឹទ្ធាចារ្យចូលរួមឲ្យចូលរួមស្តាប់ និងផ្តល់យោបល់ដល់អង្គប្រជុំ ដើម្បីបានដឹង និងទទួលយកអនុសាសន៍ពីបញ្ហាប្រឈមនានាដែលកើតមាននៅមូលដ្ឋាន ងាយស្រួលដោះស្រាយ និងចាត់វិធានការបានទាន់ពេលវេលា
- ត្រូវរកយុទ្ធសាស្ត្រអោយប្រជាពលរដ្ឋ និងសង្គមស៊ីវិលបាលចូលរួមក្នុងកិច្ចប្រជុំប្រចាំខែ និងត្រូវរៀបចំកិច្ចប្រជុំបន្ទាន់ដើម្បីដោះស្រាយបញ្ហាកើតមានក្នុងមូលដ្ឋានដូចជា គ្រោះមហន្តរាយ ឬការទប់ស្កាត់បទល្មើសនានា
- ត្រូវប្រមូលរបាយការណ៍អោយបានគ្រប់ជ្រុងជ្រោយបញ្ចូលក្នុងរបាយការណ៍ប្រចាំខែ ដូចជា ការងារសន្តិសុខ ស្ថានភាពចំណូលចំណាយ សកម្មភាពមន្ទីរ អង្គការទាំងអស់ដែលកំពុងធ្វើសកម្មភាពក្នុងឃុំ។

### ១.២. ការផ្ទេរសិទ្ធិរបស់មេឃុំ ចៅសង្កាត់

- ការផ្ទេរសិទ្ធិរបស់លោកមេឃុំ ចៅសង្កាត់ ត្រូវធ្វើ ឱ្យបានត្រឹមត្រូវជាលាយលក្ខណ៍អក្សរតាមនីតិវិធីរដ្ឋបា លឃុំ សង្កាត់ និងតាមឋានានុក្រមនៃអ្នកទទួលការផ្ទេរសិទ្ធិ ចំណែកឯ ត្រារដ្ឋបាល

ឃុំ សង្កាត់ ត្រូវរក្សាដោយស្មៀននៅសាលាឃុំ សង្កាត់ ដើម្បីឱ្យពួកគាត់បានបំពេញតួនាទីភារកិច្ច ជំនួសអ្នកផ្ទេរសិទ្ធិមានប្រសិទ្ធភាពខ្ពស់

- គ្រប់ពេលវេលាដែលលោកមេឃុំ ចៅសង្កាត់មិនបាននៅសាលាឃុំ សង្កាត់ ចាប់ពីមួយថ្ងៃឡើងទៅ គួរធ្វើការផ្ទេរសិទ្ធិដល់ជំទប់តាមឋានានុក្រមនៃការផ្ទេរសិទ្ធិ ដើម្បីអ្នកទទួលសិទ្ធិបានធ្វើការសម្រេចចិត្តបំពេញតួនាទី ក្នុងនាមជាស្តីទី ជៀសវាងការរាំងស្ទះការងារឃុំសង្កាត់
- កន្លងមកលោកមេឃុំ ចៅសង្កាត់បានផ្ទេរសិទ្ធិបានល្អតែអ្នកទទួលការផ្ទេរសិទ្ធិ អនុវត្តមិនសូវបានល្អ ដូច្នេះសុំអោយក្រុមប្រឹក្សាដែលបានទទួ លការផ្ទេរសិទ្ធិ គោរពបទបញ្ជាផ្ទៃក្នុង ចេះសុំយោបល់ចំពោះអ្នកដែលបានផ្ទេរសិទ្ធិ ឬពិគ្រោះយោបល់ជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ផ្សេងៗទៀត។ លើសពីនេះ អ្នកទទួលសិទ្ធិ ត្រូវទទួលខុសត្រូវក្នុងតួនាទីភារកិច្ចរបស់ខ្លួនចំពោះមុខច្បាប់
- ថ្នាក់ជាតិ និងស្ថាប័ននានាគួរជូនដំណឹង ឬចេញលិខិតបេសកកម្មមុនពីរ ឬ បីថ្ងៃ ដើម្បីមេឃុំបានផ្ទេរសិទ្ធិត្រឹមត្រូវ។

## ១.៣. លិខិតចេញ-ចូល

- គួរខិតខំស្វែងយល់អំពីនីតិវិធីនៃការរៀបចំបង្កើតដីកា ឬសេចក្តីសម្រេច និងលិខិត បទដ្ឋានគតិយុត្តិផ្សេងៗអោយបានស៊ីជម្រៅ
- ការបង្កើតដីកា ឬសេចក្តីសម្រេច ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមគោលការណ៍ និងនិតិវិធី ទើបមានប្រសិទ្ធភាពក្នុងការងារ
- ដើម្បីឱ្យកិច្ចការរដ្ឋបាលឃុំ សង្កាត់ដំណើរការបានរលូន និងត្រឹមត្រូវ លោកមេឃុំ ចៅសង្កាត់ត្រូវចាត់ចែងឱ្យស្មៀនរៀបចំសៀវភៅចុះលេខលិខិតចេញ-ចូលឲ្យបានត្រឹមត្រូវ និង តម្កល់ទុកជាឯកសារឱ្យមានសណ្តាប់ធ្នាប់
- មុនចេញដីកា ឬសេចក្តីសម្រេចនានា ក្រុមប្រឹក្សាឃុំ សង្កាត់គួរពិនិត្យមើលឱ្យបានច្បាស់លាស់ដើម្បីឱ្យប្រាកដថាតើស្របតាមនីតិវិធី និងមិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធឡើយ
- រាល់លិខិតចេញ ចូលត្រូវចុះក្នុងសៀវភៅ ហើយបញ្ចូលក្នុងក្រូណូតាមប្រភេទឯកសារនីមួយៗ និងចុះថ្ងៃខែដើម្បីងាយស្រួលស្វែងរក
- ពេលទទួលបានលិខិតចូល ស្មៀន ឃុំ សង្កាត់ ត្រូវវាយត្រាចូល និងបំពេញថ្ងៃខែលិខិត ដាក់ជូនមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ចុះហត្ថលេខា ដើម្បីជៀសវាងថាខ្លួនមិនបានដឹង។ ម៉្យាងវិញទៀត លិខិតរដ្ឋបាលដែលចេញដោយឃុំ សង្កាត់ ត្រូវមានលេខឃុំ សង្កាត់ ថ្ងៃខែច្បាស់លាស់ (រាល់លិខិតចេញចូលត្រូវទុកជាឯកសារ)

- ត្រូវរៀបចំលិខិតអញ្ជើញឱ្យបានគ្រប់ពេលអាណត្តិប្រជុំ និងចុះលេខក្នុងសៀវភៅចុះលេខចេញ-ចូលលិខិត ឱ្យបានត្រឹមត្រូវច្បាស់លាស់ជាប្រចាំ
- ករណីប្រគល់លិខិតអោយភាគីណាមួយ ត្រូវអោយចុះហត្ថលេខាទទួលនៅក្នុងសៀវភៅបញ្ជូនលិខិតច្បាស់លាស់។ បើបញ្ជូនលិខិតទៅអ្នកនៅឆ្ងាយពីខេត្តដែលមិនបានទទួលផ្ទាល់ដៃ ស្មៀនត្រូវផ្តល់ដំណឹងតាមទូរស័ព្ទដោយសរសេរថ្ងៃខែ ម៉ោង និងអ្នកឈ្មោះអ្នកទទួលក្នុងលិខិតនោះ នឹងទុកជាឯកសារយោង
- ករណីត្រូវរក្សាទុកដាក់សៀវភៅចេញ-ចូលតាមឆ្នាំ និងពេលដាច់ឆ្នាំ ត្រូវចារបិទសៀវភៅដោយមេឃុំ ចៅសង្កាត់ ហត្ថលេខាបញ្ជាក់៖បិទហើយឆ្នាំថ្មីត្រូវសរសេរពីលេខរៀង០០១វិញ។

## ១.៤. ការគ្រប់គ្រងទ្រព្យសម្បត្តិឃុំ សង្កាត់

- ត្រូវចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពនូវបញ្ជីសារពើភ័ណ្ឌរាល់ទ្រព្យសម្បត្តិឃុំ សង្កាត់ឱ្យបានច្បាស់ និងទៀងទាត់ ហើយត្រូវមានការថែរក្សា ឬជៀសវាងការបាត់បង់ដោយគ្មានមូលហេតុ
- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានស្មារតីទទួលខុសត្រូវទាំងអស់គ្នាក្នុងការជួយថែរក្សាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ឱ្យដូចជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនម្នាក់ៗ និង គួរបង្កើតបទបញ្ជាផ្ទៃក្នុងស្តីពីការគ្រប់គ្រងប្រើប្រាស់ថែរក្សាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់
- គួរបង្កើតអោយមានគណៈកម្មការគ្រប់គ្រងទ្រព្យសម្បត្តិ និងត្រូវធ្វើការត្រួតពិនិត្យទ្រព្យសម្បត្តិជាប្រចាំឱ្យបានទៀងទាត់ និងធ្វើបច្ចុប្បន្នភាពចុះបញ្ជីប្រចាំឆ្នាំឱ្យបានត្រឹមត្រូវ ។ លើសពីនេះទ្រព្យសម្បត្តិទាំងអស់របស់ឃុំ សង្កាត់ គួរបង់ ឱ្យមានលេខកូដឱ្យបានត្រឹមត្រូវ ហើយ គួរមានលិខិតច្បាស់លាស់ ពេលមានការជួល ឬខ្ចីសម្ភារៈទាំងនោះ និងពិនិត្យពេលយកត្រឡប់មកវិញ
- ត្រូវមានរបាយការណ៍សង្ខេបស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិឃុំ-សង្កាត់ មានកាលបរិច្ឆេទតាមឆ្នាំដោយបែងចែកជាបីប្រភេទដូចជាប្រភេទទី១៖ទ្រព្យសម្បត្តិឃុំទិញដោយថវិកាខ្លួន ប្រភេទទី២៖ បានមកពីអាជ្ញាធរខេត្តផ្ទេរសិទ្ធិឱ្យកាន់កាប់ ប្រភេទទី៣ ៖ជាអំណោយដែលផ្តល់ដោយបុគ្គលក្រុមហ៊ុនឯកជន អង្គការសង្គមស៊ីវិល និងសប្បុរសជនឱ្យមកឃុំ -សង្កាត់។ ករណីមានការបាត់បង់ត្រូវជូនដំណឹងទៅអ្នកពាក់ព័ន្ធជាបន្ទាន់ និងឆ្លើយតបនឹងបញ្ជីរសារពើភ័ណ្ឌ
- ឃុំ សង្កាត់ត្រូវពិនិត្យមើលសារឡើងវិញនូវបញ្ជីឯកសារសាពើពន្ធ័របស់ខ្លួនឱ្យច្បាស់លាស់ និងផ្ញើរជូនទៅសាលា ក្រុង ស្រុកជារៀងរាល់ឆ្នាំ។

## ១.៥. ការគ្រប់គ្រង និងប្រើប្រាស់ឯកសារ

- ឯកសារត្រូវដាក់នៅសាលាឃុំ សង្កាត់ ក្នុងក្រូណូស៊ីមី ទូ តាមទីកន្លែងតាមឆ្នាំ និងប្រភេទនៃឯកសារ (ស្មៀន អ្នកទទួលខុសត្រូវ) ១ឆ្នាំចងក្រងទុកម្តងនៅកន្លែងមានសុវត្ថិភាព
- រាល់បណ្តាឯកសារដែលបានទទួលពីថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ក្រុង ត្រូវចុះលេខចូល និងថតចម្លងចែកចាយ បើសិនជាក្នុងករណីចាំបាច់ត្រូវប្រជុំផ្សព្វផ្សាយ ឱ្យអ្នកពាក់ពន្ធ័បានដឹងឮផងហើយរៀបចំទុកដាក់ឯកសារឱ្យបានគង់វង្សដើម្បីងាយស្រួលរកនៅពេលដែលត្រូវការ
- គួរត្រូវបង្កើតឱ្យមានបណ្ណាល័យ ដើម្បី ឱ្យប្រជាពលរដ្ឋ និងមហាជនងាយស្រួលចូលមើល និងស្រាវជ្រាវ។ បើអាចគួរមានកុំព្យូទ័រដើម្បីរក្សាទុកឯកសារ

- សូមឱ្យរដ្ឋាភិបាលជួយកសាងសាលាឃុំ សង្កាត់ឱ្យ បានត្រឹមត្រូវចំពោះឃុំ សង្កាត់ ដែលមិនទាន់មានសាលាឃុំ សង្កាត់
- ឯកសារទាំងអស់ត្រូវទុកនៅក្នុងសាលាឃុំ សង្កាត់ មិនត្រូវទុកនៅកន្លែងផ្សេងៗខុសពីសាលាឃុំ សង្កាត់ឡើយ និងឯកសារប្រើប្រាស់ និងពិនិត្យហើយ សូមយកមកដាក់សាលាឃុំ សង្កាត់វិញឱ្យទាន់ពេលវេលា។

## ១.៦. ការផ្សព្វផ្សាយព័ត៌មាន

- គួរបង្កើនឱ្យមានក្តារព័ត៌មាននៅសាលាឃុំ សង្កាត់ នៅទីសាធារណៈ ទីប្រជុំជន និងនៅតាមភូមិគ្រប់ភូមិ ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានឃុំ សង្កាត់ឱ្យបានទូលំទូលាយ
- ព័ត៌មានគួរត្រូវបានផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបានទាន់ពេលដល់ប្រជាពលរដ្ឋតាមគ្រប់រូបភាពដូចជាៈ បិទបដារូបភាព បិទប្រកាសផ្សព្វផ្សាយតាមភូមិ ចាក់មេក្រូប្រជុំតាមភូមិ ឬ ឱ្យលោកមេភូមិ ក៏ដូចជាគណៈកម្មាធិការអភិវឌ្ឍន៍ភូមិជម្រាបផ្ទាល់តាមក្រុម និងតាមគ្រួសារ និងត្រូវស្វែងរកវិធីសាស្ត្រផ្សេងៗទៀតក្នុងការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋដើម្បីឱ្យពួកគាត់អាចចាប់អារម្មណ៍ និងងាយទទួលយកបាន
- គួររៀបចំឱ្យមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ០ ១នាក់ទទួលបន្ទុកជំរុញការផ្សព្វផ្សាយ និងបង្កើតបណ្តាញតាមភូមិ និង គួររៀបចំឱ្យមានឧឃោសនស័ព្ទ មួយគ្រឿងនៅសាលាឃុំ សង្កាត់ និងនៅតាមភូមិដើម្បីធ្វើការផ្សព្វផ្សាយ ព្រមទាំង គួររិះរកវិធីសាស្ត្រផ្សេងទៀត ដែលទាក់ទាញប្រជាពលរដ្ឋអោយចូលរួមស្តាប់ព័ត៌មាន ។

## ១.៧. ទំនាក់ទំនងជាមួយស្ថាប័ន អង្គការពាក់ព័ន្ធ

- ស្វែងយល់ពីការកសាងភាពជាដៃគូជាមួយនឹងស្ថាប័ន និងអង្គភាពពាក់ពន្ធ័នានា ។ លើសពីនេះ ត្រូវសហការឱ្យបានជាប់ជាប្រចាំក្នុងការអនុវត្តការងារអភិវឌ្ឍន៍នានាក្នុងមូលដ្ឋាន
- គួរបង្កើនទំនាក់ទំនងជាមួយស្ថាប័ន និងអង្គការពាក់ព័ន្ធនានា ឱ្យបានជិតស្និទ្ធបន្ថែមទៀត ដើម្បីគៀរគរធនធានមកធ្វើការអភិវឌ្ឍន៍មូលដ្ឋានឱ្យមានការរីកចំរើន
- ក្រុមប្រឹក្សាឃុំ សង្កាត់ គួរយកចិត្តទុកដាក់លើការងារទំនាក់ទំនងការសហការណ៍ជាមួយនឹងមន្ទីរជំនាញ អង្គការជាតិ អន្តរជាតិ សប្បុរសជនដែលបាន និងកំពុងគ្រាំទ្រគម្រោងអភិវឌ្ឍន៍ឃុំសង្កាត់របស់ខ្លួន
- ឃុំ សង្កាត់មួយចំនួនធំមិនមានថវិកាសម្រាប់ដាក់ក្តារព័ត៌មានតាមភូមិបន្ត និងខ្វះមធ្យោបាយ និងសម្ភារៈ ថវិកា ដើម្បីផ្សព្វផ្សាយព័ត៌មានអោយបានទូលំទូលាយ និង គួរផ្លាស់ប្តូរព័ត៌មានឱ្យបានញឹកញាប់ដល់ប្រជាពលរដ្ឋ។

## ១.៨. របាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ

- គួរចាត់តាំងអោយក្រុមប្រឹក្សាណាម្នាក់ទទួលខុសត្រូវ ត្រួតពិនិត្យរបាយការណ៍ដែលស្មៀនបានរៀបចំ ដើម្បីធានាឱ្យការចេញរបាយការណ៍ឃុំ សង្កាត់ ទៅទីចាត់ការផែនការ និងវិនិយោគបានទាន់ពេលវេលា និងបានត្រឹមត្រូវល្អ
- គួរពង្រឹងការទទួលខុសត្រូវ និងគុណភាពរបាយការណ៍បន្ថែមទៀតដែលផ្ញើជូនក្រុមប្រឹក្សាឃុំសង្កាត់ និងស្នើសុំឱ្យ មានការធ្វើបច្ចុប្បន្នភាពកែប្រែជាថ្មីនូវទម្រង់របាយការណ៍រីកចំរើនប្រចាំខែ

ប្រចាំឆ្នាំរបស់ឃុំ សង្កាត់ដែលត្រូវផ្ញើរទៅជូនស្រុក ក្រុង និងខេត្ត នោះឱ្យបានសមស្របទៅតាមស្ថានភាពជាក់ស្តែង

- របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំរបស់ឃុំ សង្កាត់ គួរផ្អែកលើផែនការតាមដានការអនុវត្តសកម្មភាពការងាររបស់ឃុំ សង្កាត់ ហើយ គ្រប់ឃុំ សង្កាត់ គួររៀបចំសរសេររបាយការណ៍តាមប្រព័ន្ធកុំព្យូទ័រ ព្រោះអាចរក្សាទុកបាន ព្រមទាំងមានភាពងាយស្រួល និងចំណេញពេលវេលា
- រាល់ពេលបូកសរុបរបាយការណ៍ប្រចាំខែម្តងៗ ក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំពិភាក្សាផ្តល់យោបល់ពីគ្នាទៅវិញទៅមកដើម្បីយកបទពិសោធ៍ល្អៗ។

## ១.៩. ការសម្របសម្រួលទំនាស់

- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវសិក្សាស្វែងយល់អំពីច្បាប់នានា ឱ្យបានច្រើន ដើម្បីបង្កើនសមត្ថភាពយល់ដឹង និងជាមូលដ្ឋានបង្អែកក្នុងការផ្តល់សេវាអន្តរាគមន៍ សម្របសម្រួល និងដោះស្រាយទំនាស់នៅមូលដ្ឋានឱ្យបានត្រឹមត្រូវ ជាពិសេសដើម្បីបង្កើនភាពជឿជាក់ដល់ប្រជាពលរដ្ឋ
- ជំរុញផ្សព្វផ្សាយច្បាប់នានាដល់ប្រជាពលរដ្ឋ ដើម្បីឱ្យពួកគាត់បានយល់បន្ថែមទៀត និងដើម្បីការពារទប់ស្កាត់កុំឱ្យមានទំនាស់ក្នុងមូលដ្ឋានរបស់ខ្លួន ព្រមទាំងគួរបែងចែកតួនាទីដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងពេលវេលាសមស្របសម្រាប់ធ្វើការផ្សព្វផ្សាយច្បាប់នានាដល់ប្រជាពលរដ្ឋ
- បណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ បន្ថែមទៀត ដើម្បីបង្កើនចំណេះដឹងអំពីច្បាប់ និងនីតិវិធីនៃការសម្រុះសម្រួល ទំនាស់ដូចជាច្បាប់រដ្ឋប្បវេណី ច្បាប់ភូមិបាល និងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារជាដើម
- ក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងអស់ត្រូវតែយកចិត្តទុកដាក់ខ្ពស់នូវរាល់បាតុភាព ឬបណ្តឹងគ្រប់ប្រភេទរបស់ប្រជាពលរដ្ឋ និងធ្វើការសម្រុះសម្រួលដោះស្រាយទំនាស់ដោយមិនត្រូវអូសបន្លាយពេលឱ្យទំនាស់នោះមានសភាពធ្ងន់ធ្ងរឡើយ
- ស្ថាប័នពាក់ព័ន្ធត្រូវជួយពង្រឹង និងបណ្តុះបណ្តាលដល់គណៈកម្មការដោះស្រាយវិវាទ និងក្រុមប្រឹក្សាឃុំ សង្កាត់ អំពីការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ជាការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលតម្រូវឱ្យធ្វើការសម្របសម្រួលភាគីទំនាស់ឱ្យស្រុះស្រួលគ្នាទៅតាមអង្គហេតុ តាមច្បាប់កំណត់ បើលើសពីនេះត្រូវតែបញ្ជូនទៅតុលាការ។

# ២. ការអនុវត្តមុខងារជាភ្នាក់ងារ

## ២.១. អត្រានុកូលដ្ឋាន

- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការបំផុស និងជំរុញជាមួយនឹងការបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ មកចុះបញ្ជីអត្រានុកូលដ្ឋានបានគ្រប់ៗគ្នាតាមគ្រប់វិធីសាស្ត្រដែលអាចធ្វើទៅបាន
- បន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ឱ្យគាត់បានយល់គ្រប់ៗគ្នាពីអត្ថប្រយោជន៍នៃការចុះអត្រានុកូលដ្ឋាន
- បង្កើនសេវាយុទ្ធនាការនៃចុះបញ្ជីអត្រានុកូលដ្ឋាន ឱ្យបានទាន់ពេលជូនប្រជាពលរដ្ឋ និងត្រូវអប់រំដល់ប្រជាពលរដ្ឋ ចេះថែរក្សាសំបុត្រអត្រានុកូលដ្ឋាន
- បណ្តុះបណ្តាលបង្កើនសមត្ថភាពដល់មន្ត្រីចុះបញ្ជីអត្រានុកូលដ្ឋានបន្ថែមទៀត

- ក្រុមប្រឹក្សាឃុំត្រូវក្តាប់អោយបានអំពីស្ថិតិប្រជាពលរដ្ឋ ដែលអ្នកបានចុះបញ្ជីអត្រានុកូលដ្ឋាន។

## ២.២. ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

- គួរធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឱ្យបានសុក្រិត្យមិនប្រកាន់ និន្នាការនយោបាយ
- ជំរុញផ្សព្វផ្សាយ និងបង្កឱកាសឱ្យប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើងទៅឱ្យមកពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ក្រុមប្រក្សាឃុំ សង្កាត់គួរយកចិត្តទុកដាក់ក្នុងការជួយស្មៀនឃុំសង្កាត់លើការងារចុះឈ្មោះ និងពិនិត្យឈ្មោះប្រជាពលរដ្ឋជារៀងរាល់ឆ្នាំ។

## ៣. ការគ្រប់គ្រងហិរញ្ញវត្ថុ

## ៣.១ ការប្រើប្រាស់មូលនិធិឃុំ សង្កាត់

- ដើម្បីឱ្យការគ្រប់គ្រងថវិកាឃុំ សង្កាត់ បានល្អ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសគម្រោងឲ្យបានសមស្រប និងមានអាទិភាពខ្ពស់ហើយចាំបាច់ដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ
- ត្រូវប្រើប្រាស់មូលនិធិឃុំ សង្កាត់ឲ្យចំទិសដៅ និងសន្សំសំចៃ
- នៅដើមឆ្នាំនីមួយៗក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំផ្សព្វផ្សាយប្រាប់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធឱ្យបានដឹងអំពីចំនួនថវិកាដែលថ្នាក់ជាតិបានវិភាជន៍ឲ្យឃុំ សង្កាត់ ទាំងប្រាក់សម្រាប់ចំណាយរដ្ឋបាល និងមូលនិធិសម្រាប់អភិវឌ្ឍន៍។

## ៣.២ ការប្រមូលទុនចូលរួមរបស់មូលដ្ឋាន

- ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ច្បាស់អំពីសារៈសំខាន់នៃទុនចូលរួម ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចុះប្រជុំផ្សព្វផ្សាយជូនប្រជាពលរដ្ឋឲ្យកាន់តែមានស្មារតីចូលរួមឱ្យបានកាន់តែច្រើនថែមទៀតពីព្រោះពួកគាត់ជាអ្នកទទួលផល និងជាម្ចាស់គម្រោង
